# មន្ទីរកសិកម្មខេត្តកណ្តាល

## ជីគីមី និងការប្រើប្រាស់




អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

ឆ្នាំ ២០១០


## ជីគីមី និងការប្រើប្រាស់

ជីគីមី គឺជាសារធាតុចិញ្ចឹមទោល ឬសមាសដែលគេប្រើ ដើម្បីបង្កើនការលូតលាស់ទិន្នផល និងគុណភាពរបស់ដំណាំ។ ជីគីមី គឺជាប្រភេទជី ដែលសំយោគ ឬផលិតចេញពីរោងចក្រ។

- ជីទោល ជាប្រភេទជីអសរីរាង្គដែលមានធាតុសកម្មតែមួយប្រភេទ។

<u>ឧទាហរណ៍</u> ជីអ៊ុយរ៉េ (៤៦-00-00)

ជីបូតាស្យូមក្លរួ (00-00-៦0)

- ជីសមាសជាប្រភេទជីអសរីរាង្គដែលមានធាតុសកម្ម ចាប់ពី ២ ប្រភេទឡើងទៅ។

<u>ឧទាហរណ៍</u> ជីដេអាប៉េ (១៨-៤៦-00)

ជីកែង-កែង (១៥-១៥-១៥)

* របៀបគណនាជីគីមីសម្រាប់ប្រើប្រាស់ក្នុងដី ១ ហិចតា

| | |
|---|---|
| បរិមាណជីប្រើ = | ធាតុចិញ្ចឹមតាមបទដ្ឋាន x ១00 |
| | ធាតុចិញ្ចឹមក្នុងដី |

**<u>ឧទាហរណ៍ទី</u>** ១ រូបមន្តក្រុមដីព្រៃខ្មែរដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{៥២}$ $P_{១៥}$ $K_{២០}$ (គក្រ/ហិចតា។

យើងប្រើជីអ៊ុយរ៉េ (N = ៤៦%) ជីដេអាប៉េ (N=១៨%) ($P_២O_៥$=៤៦%) និង ជីប៉ូតាស្យូមក្លរួ ($K_២O$=៦0%)។

<u>ជាដំបូងយើងត្រូវគណនារក $K_{២០}$</u> (គក្រ) ពីជីប៉ូតាស្យូមក្លរួ

$$K_{20}\ (គក្រ) = \frac{២00 \times ១00}{៦0} = ៣៣,៣៣\ គក្រ$$

<u>បន្ទាប់មកយើងគណនារក $P_{១៥}$</u> (គក្រ) <u>ពីជីដេអាប៉េ</u>

$$P_{15}\ (គក្រ) = \frac{១៥ \times ១00}{៤៦} = ៣២,៦0គក្រ$$

ក្នុងជីដេអាប៉េ ១00គក្រ មានធាតុ N = ១៨គក្រ ដូច្នេះ

ក្នុងជីដេអាប៉េ ៣២,៦0គក្រ មានធាតុ Nគក្រ

$$N\ (គក្រ) = \frac{១៨ \times ៣២,៦0}{១000} = ៥,៨៦គក្រ\ (= ៦\ គក្រ)$$

នាំអោយយើងនៅសល់

$N_{52}$ $P_{15}$ $K_{20}$

\- $N_{6}$ $P_{15}$ $K_{20}$

$N_{46}$ $P_{0}$ $K_{0}$ ត្រូវគណនា

<u>ចុងក្រោយយើងគណនារក $N_{៤៦}$ (គក្រ) ពីជីអ៊ុយរ៉េ</u>

$$N_{46}\ (គក្រ) = \frac{៤៦ \times ១00}{៤៦} = ១00គក្រ$$

**ជាចំលើយរូបមន្តដីព្រៃខ្មែរ $N_{៥២}$ $P_{១៥}$ $K_{២០}$** (គក្រ/ហត)

យើងប្រើជីៈ

- ប៉ូតាស្យូមក្លរួ (គជល) = **<u>៣៣,៣៣ គក្រ</u>**
- ដេអាប៉េ (AB) = **<u>៣២,៦0 គក្រ</u>**
- អ៊ុយរ៉េ (Ure) = **<u>១00 គក្រ</u>**

**ឧទាហរណ៍ទី ២** រូបមន្តក្រុមដីប្រទះឡាងដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{60}$ $P_{29}$ $K_{30}$ (គក្រ/ហិចតា)។ ជាចំលើយគឺយើងប្រើជីៈ

- ជីប៉ូតាស្យូមក្លរួ (គជល) = **<u>៥0 គក្រ</u>**
- ជីដេអាប៉េ ((AB) = **<u>៦៣ គក្រ</u>**
- ជីអ៊ុយរ៉េ (Ure) = **<u>១០៦,៥0 គក្រ</u>**

**ឧទាហរណ៍ទី ៣** រូបមន្តក្រុមដីបាកានដែលប្រើពូជស្រូវទំនើបនឹងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{70}$ $P_{30}$ $K_{15}$ (គក្រ/ហិចតា)។ ជាចំលើយគឺយើងប្រើជីៈ

-ជីប៉ូតាស្យូមក្លរួ (គជល) = **<u>២៥ គក្រ</u>**

-ជីដេអាប៉េ ((AB) = **៦៥ គក្រ**

-ជីអ៊ុយរ៉េ (Ure) = **១២៧ គក្រ**

**ឧទាហរណ៍ទី ៤** រូបមន្តក្រុមដីក្បាលពោធិដែលប្រើពូជស្រូវទំនើបនិងអាចគ្រប់គ្រងទឹកបានល្អគឺ $N_{120}$ $P_{34}$ $K_0$ (គក្រ/ហិចតា) ។ ជាចំលើយគឺយើងប្រើជី៖

-ជីដេអាប៉េ (AB) = **៧៤ គក្រ**

-ជីអ៊ុយរ៉េ (Ure) = **២៣២ គក្រ**

១-ដើម្បីប្រើប្រាស់ជីគីមីឱ្យមានប្រសិទ្ធិភាពយើងត្រូវគិតពី៖

-ដី តើដីនោះប្រភេទដីអ្វី

-ពូជ តើយើងប្រើពូជក្នុងស្រុក (ពូជប្រពៃណី ) ឬពូជទំនើប (ពូជបង្កាត់ )

-រដូវកាលដាំដុះ តើយើងធ្វើការដាំដុះនៅរដូវណា (រដូវប្រាំង ឬ រដូវវស្សា )

-ទឹក ស្រែមានទឹក ឬ ស្រែគ្មានទឹក

-ស្មៅ មុនពេលបាចជីត្រូវបោចស្មៅឱ្យអស់ពីក្នុងស្រែ

-ដំណាក់កាលលូតលាស់ តើដល់ដំណាក់កាលណាហើយ

-កំរិតប្រើប្រាស់ជី អាស្រ័យទៅតាមក្រុមដី (តាមសៀវភៅជីសំរាប់ផលិតកម្មស្រូវនៅកម្ពុជា (CARDI) ។

**២-តួនាទីរបស់ធាតុ N-P-K**

-N ជួយស្លឹកអោយមានពណ៌បៃតងក្រម៉ៅ ជំរុញការលូតលាស់ដើមបែកគុម្ពល្អ

-P ជួយប្រព័ន្ធដល់ឫស ជំរុញឱ្យឆាប់ចេញផ្កា និងមានភាពទុំល្អ បង្កើនគុណភាពគ្រាប់

-K ជួយឱ្យដើមស្រូវមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ ជំរុញការបែកគុម្ព បង្កើនទំហំ និងទំងន់គ្រាប់ ។

**៣-ការបាចជីលើស្រែសន្ទូង និងពង្រួស**

➢ ការបាចជីលើស្រែសន្ទូងចែកចេញ ៣ លើកគឺ៖

- លើកទី១ បាចទ្រាប់បាត ប្រើជីធម្មជាតិ ១០០% ជីដេអាប៉េ ១០០% ជីអ៊ុយរ៉េ ៣០%
- លើកទី២ បាចបំប៉នក្រោយពីស្ទូង ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយស្ទូង ១០-១៥ថ្ងៃ
  - ស្រូវកណ្តាល ក្រោយស្ទូង ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយស្ទូង ៣០-៣៥ថ្ងៃ
- លើកទី៣ បាចបំប៉នពេលស្រូវចាប់ផ្តើមកំណកំណើតកួរ ប្រើជីអ៊ុយរ៉េ ៤០%

➢ ការបាចជីលើស្រែពង្រួសចែកចេញ ៤ លើកគឺ៖

- លើកទី១ បាចទ្រាប់បាត (ពេលភ្ជួរ-រាស់ព្រួស) ប្រើជីធម្មជាតិ ១០០% ជីដេអាប៉េ ១០០%
- លើកទី២ បាចបំប៉នក្រោយព្រួស, ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយព្រួស ១០-១៥ថ្ងៃ
  - ស្រូវកណ្តាល ក្រោយព្រួស ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយព្រួស ២៥-៣០ថ្ងៃ
- លើកទី៣ បាចក្រោយបំប៉នលើកទី ២ ជីអ៊ុយរ៉េ ៣០%
  - ស្រូវស្រាល ក្រោយបំប៉នទីពីរ ១៥-២០ថ្ងៃ
  - ស្រូវកណ្តាល ក្រោយបំប៉នទីពីរ ២០-២៥ថ្ងៃ
  - ស្រូវធ្ងន់ ក្រោយបំប៉នទីពីរ ២៥-៣០ថ្ងៃ
- លើកទី៤ បាចបំប៉នពេលស្រូវចាប់ផ្តើមកំណកំណើតកួរ ប្រើជីអ៊ុយរ៉េ ៤០% ។

**៤-ពេលវេលាបាចជី**

-បាចជីពេលព្រឹក ឬពេលល្ងាច អាស្រ័យតាមអាកាសធាតុ

-គួរបាចជីនៅពេលស្លឹកស្រូវស្ងួត ។

**៥-កត្តាគួរជៀសវាង**

-ហាមបាចជីក្រោយពេលភ្លៀង ឬពេលស្លឹកស្រូវនៅសើម

- មុនពេលភ្លៀងធ្លាក់មិនត្រូវបាចជីឡើយ

-ហាមបាចជីលើស្រែមានទឹកច្រើនពេក ឬគ្មានទឹក

-ហាមបាចជីពេលស្រូវកំពុងមានជំងឺ ឬសត្វល្អិតបំផ្លាញ

-ហាមបាចជីលើស្រែដែលមានស្មៅដុះច្រើន

-ហាមបាចជីអោយលើសពីសេចក្តីត្រូវការរបស់ស្រូវ... ។

